00858681

002/19-09-2007-ECCC/TC
E1/132

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06 / 11 / 2012
ម៉ោង (Time/Heure): 16:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ អង្គារ ទី ០៩ ខែ តុលា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី- ថ្ងៃទី ១១៩

រៀបចំដោយ: ដាវ អានសាន និង Matteo CRIPPA

| |
|---|
| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក Matteo CRIPPA, លោក ដាវ អានសាន |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Tarik Abdulhak, លោក វេង ហ៊ត់, លោក Keth Reynor |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZZI |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក វ៉ែន ពៅ, លោក ឡោ ជុនធី, លោកស្រី ស៊ិន សុវ៉ន |
| សាក្សី៖ លោក មាស វឿន (TCW-428) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក សេង រិទ្ធី (មេធាវីប្រឹក្សាសាក្សី), កញ្ញា Anne-Elise JOLICARD |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៦.១៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៤០ | បញ្ចប់ម៉ោង៖ ១១.០០ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.១០ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤៥ | បញ្ចប់ម៉ោង៖ ១៥.១០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ៥ ម៉ោង ៥ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការតាំងសំណួរទៅសាក្សី មាស វឿន (TCW-428) | មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.០៧<br>១០.២៣<br>១១.០៣ | ១០.២២<br>១០.៣៧<br>១៥.៣៧ |
| សេចក្តីសម្រេចលើការតាំងសំណួរចំពោះសាក្សី ដែលមិនផ្អែកលើភស្តុតាង | អង្គជំនុំជម្រះ | ១០.១១ | ១០.១៣ |
| ការស្នើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការ | មេធាវីការពារក្តី នួន ជា | ១២.១១ | ១២.១២ |
| ការអានដីកាដំណោះស្រាយ | ក្រឡាបញ្ជីអង្គជំនុំជម្រះ | ១៥.៤១ | ១៦.០៩ |
| សេចក្តីសម្រេចផ្ទាល់មាត់លើអាកប្បកិរិយាមេធាវីការពារក្តី | អង្គជំនុំជម្រះ | ១៦.១០ | ១៦.១២ |

## សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖

**ការតាំងសំណួរទៅសាក្សី មាស វឿន (TCW-428)**

មេធាវីការពារក្ដី នួន ជា បន្ត និងបញ្ចប់ការតាំងសំណួរ ទៅសាក្សី មាស វឿន ។ បន្ទាប់មក ការតាំងសំណួរបន្តដោយក្រុមមេធាវីការពារក្ដី អៀង សារី និង មេធាវីការពារក្ដី ខៀវ សំផន ជាបន្តបន្ទាប់ ។

**សេចក្ដីសម្រេចលើការតាំងសំណួរចំពោះសាក្សី ដែលមិនផ្អែកលើភស្តុតាង**

អង្គជំនុំជម្រះសម្រេចថា សំណួរដេញដោលឯណា ដែលមិនផ្អែកលើសម្ភារៈ ឬ កំណត់ហេតុសួរចម្លើយសាក្សី ដែលមិនត្រូវបានបង្ហាញនៅចំពោះមុខតុលាការ គឺមិនអាចធ្វើឡើងបានឡើយ។ សវនាការដំណើរការដោយផ្អែកលើតែភស្តុតាងប៉ុណ្ណោះ។ ជាលទ្ធផល ប្រសិនបើមានកំណត់ហេតុសួរយកចម្លើយសាក្សីពីមុន ដែលត្រូវបានបង្ហាញ និងសួរដេញដោលនៅក្នុងសវនាការរួចហើយ ឬជាឯកសារដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនោះ ឯកសារទាំងនេះអាចយកធ្វើជាមូលដ្ឋាននៃការតាំងសំណួរចំពោះសាក្សីបាន។ ការណែនាំពីជនជាប់ចោទ មិនមានទម្ងន់ច្រើនឡើយ លើកលែងតែជនជាប់ចោទសម្រេចមិនរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបទៅនឹងការសួរដេញដោល។

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដំណើរការសវនាការ**

ជនជាប់ចោទ នួន ជា តាមរយៈមេធាវីរបស់គាត់ (ម៉ោង ១២.១១) បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដំណើរការសវនាការដោយផ្ទាល់សម្រាប់ពេលរសៀល។ អង្គជំនុំជម្រះយល់ព្រមតាមការស្នើសុំ។

**ការអានដីកាដំណោះស្រាយ**

ក្រឡាបញ្ជីជាតិ អានកថាខណ្ឌដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងមូលដ្ឋានឧក្រិដ្ឋកម្មការសម្លាប់មន្ត្រីរដ្ឋការ លន់ នល់ និងកន្លែងសម្លាប់មនុស្ស ទួលពោធិជ្រៃ ស្របតាមវិធាន ៨៩ស្ទួន នៃវិធានផ្ទៃក្នុង និង អនុស្សរណៈរបស់ អជសដ ឯកសារលេខ E163/5 និង E124/7.3។ កថាខណ្ឌ ដែលត្រូវបានអានគឺ ២០៥-២០៩, ៦៩៨-៧១១, ៩៧៥-៩៧៧, ១១០៥-១១១៣, ១១៩១-១១៩៣។

**សេចក្ដីសម្រេចលើអាកប្បកិរិយា របស់មេធាវីការពារក្ដី Andrew IANUZZI**

អង្គជំនុំជម្រះធ្វើសេចក្ដីសម្រេចផ្ទាល់មាត់លើអាកប្បកិរិយាមិនសមស្របរបស់មេធាវីការពារក្ដី នួន ជា លោក Andrew IANUZZI។ កាយវិការប្រមាថដល់អង្គជំនុំជម្រះគឺជាការមិនគោរពក្រមសីលធម៌វិជ្ជាជីវៈ។ អង្គជំនុំជម្រះនឹងបញ្ជូនពាក្យប្ដឹងរបស់ខ្លួនទៅគណៈមេធាវី និងស្នើឲ្យគណៈមេធាវីរបស់មេធាវីការពារក្ដី

IANUZZI ធ្វើការពិចារណាលើពាក្យបណ្ដឹងរបស់ខ្លួន រួមជាមួយនឹងការប្ដឹងដែលបានចេញពីពេលមុនចំពោះរូបគាត់។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in France |
|---|---|---|---|---|---|---|---|
| E3/424 | D234/25 | 00418517-00418523 00421068-00421074 00455266-00455272 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន MEAS Voeun [Corrected 1] Written Record of Interview of MEAS Voeun មាស វឿន [Corrigé 2] Procès verbal d'audition de témoin MEAS Voeun មាស វឿន | P | 00418521 | 00421072 | 00455270 |
| N/A | E142/3 | 00788412-00788423 00788404-00788411 00792752-00792760 | សេចក្ដីសម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សីរបស់ក.ស.ច.ស [Corrected 1] Decision on NUON Chea's request for a rule 35 investigation regarding inconsistencies in the audio and written records of OCIJ witness interviews Décision relative à la requête de NUON Chea concernant les enregistrements audio | P | | | |
| E3/80 | D369/7 | 00486468-00486473 00491653-00491658 00509783-00509789 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី MEAS Voeun មាស វឿន ចុះថ្ងៃទី 03-03-2010 [Corrected 1] Written Record of Interview of Witness MEAS Voeun មាស វឿន dated 03-03-2010 [Corrigé 2] Procès verbal d'audition de témoin MEAS Voeun មាស វឿន en date du 03-03-2010 | P | 00486472 | 00491657 | 00509787-00509788 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/1755 | D369/7.2 | 00852112-00852121 00853547-00853556 | ផ្នែកមួយនៃប្រតិចារឹកបទសម្ភាសន៍រវាងអ្នកស៊ើបអង្កេត និងលោក មាស វឿន ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១០ Partial Transcript of recorded interview by investigator with Mr. MEAS Voeun dated 03 March 2010 | P | | | |
| E3/1756 | D359/1/1.1.1 | 00851604-00851608 00852373-00852375 | ឧបសម្ព័ន្ធ ០១៖ គោលនយោបាយ យោធា និង សេដ្ឋកិច្ចអភិវឌ្ឍន៍ប្រទេសកម្ពុជា ១៩៧០-៧៣ Annex 1: Political, military and economic development Cambodia 1970-73 | P | 00851605, 00851607 | 00852374, 00852375 | 00535853, 00535855 |
| E3/425 | D234/26 | 00418567-00418571 00421611-00421615 00455273-00455277 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង គឹមអឿន SĒNG Kimoeun [Corrected 1] Written Record of Interview of SĒNG Kimoeun សេង គឹមអឿន [Corrigé 1] Procès verbal d'audition de témoin SĒNG Kimoeun សេង គឹមអឿន | P | | | |
| E3/411 | D232/9 | 00373506-00373517 00390073-00390082 00424032-00424044 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល SUON Kanil ថ្ងៃទី ១៩-០៨-២០០៩ [Corrected 1] Written Record of Interview of SUON Kanil សួន កានិល dated 19-08-2009 Procès verbal d'audition de témoin SUON Kanil សួន កានិល dated 19-08-2009 | P | 00373510 | 00390077 | 00424036 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនសាក្សី TCW-428 ត្រឡប់ទៅកាន់គោលដៅដែលគាត់មានបំណងចង់ទៅ ដោយសក្ខីកម្មរបស់គាត់បានបញ្ចប់ និងលែងមានភាពចាំបាច់ទៀតហើយ។

- អង្គជំនុំជម្រះធ្វើសេចក្តីសម្រេចផ្ទាល់មាត់លើអាកប្បកិរិយាមិនសមស្របរបស់មេធាវីការពារក្តី នួន ជា លោក IANUZZI ។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩.០០ ព្រឹក ថ្ងៃ អង្គារ៍ ទី ០៩ ខែ តុលា ឆ្នាំ ២០១២។

| <u>កាលបរិច្ឆេទបន្តសវនាការ៖</u> |
| --- |
| សវនាការនឹងបន្តនៅថ្ងៃ ពុធ ទី ១០ ខែ តុលា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២

ក្រឡាបញ្ជី[illegible]បញ្ជី

**ដាច អានសា[illegible]** Matteo CR[illegible]A